ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី

លេខ : ៤០

ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៩៨

**សាលដីកា**

លេខ : ៤១

ចុះថ្ងៃទី ០៣ ខែមីនា ឆ្នាំ២០០៣

**នាមនាមប្រជារាស្ត្រខ្មែរ**

**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៣ ដោយមានសមាសភាព ដូចតទៅ :

១- ឯកឧត្តម ឃឹម ប៊ុណ្ណ ជាប្រធាន

២- លោក ប៉ែន សាវឿន ជាចៅក្រម

៣- លោក គង់ ភិរុន ជាចៅក្រម

៤- លោក ស៊ិន ឌីម ជាចៅក្រម-របាយការណ៍

៥- លោក ជីវ កេង ជាចៅក្រម

៦- លោក ឈឹម ស៊ីផល ជាចៅក្រម

៧- លោក សោម សិរីវឌ្ឍ ជាចៅក្រម

៨- លោក ប្រាក់ គីមសាន ជាចៅក្រម

៩- លោក យស់ សូខឿន ជាចៅក្រម

ក្រឡាបញ្ជី

លោក ស៊ិន ភារ:

តំណាងមហាអយ្យការ

លោក ឈួន ចាន់ថា, ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាលេខ៩៥៤ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ ១៩៩៧ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៣៨ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ១៩៩៥ របស់សាលាឧទ្ធរណ៍ ។

- រវាងដើមចោទឈ្មោះវ័ន្ត សុវណ្ណរិទ្ធិ "ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស អាយុ៤០ឆ្នាំ ជាតិខ្មែរ មុខរបរ ក្រឡាបញ្ជីតុលាការខេត្តកណ្តាល ទីលំនៅសព្វថ្ងៃផ្ទះលេខ៤៨ED ក្រុមទី៤៨ សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ។ ឪពុកឈ្មោះឆេង ស៊ុនថៃ "ស្លាប់" ម្តាយឈ្មោះ សូ ផានី "ស្លាប់" ប្រពន្ធ ឈ្មោះ យុន ណារ៉េន មានកូន០១នាក់ ។

-មានមេធាវីលោក ស៊ឹម ស៊ីថាន

- និងចុងចម្លើយឈ្មោះ អ៊ុក ម៉ាលីស "ជាចុងបណ្ដឹងសាទុក្ខ" ភេទស្រី អាយុ ៥៥ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ មានទីលំនៅសព្វថ្ងៃភូមិលើ ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្ដាល ។

**កម្មវត្ថុ** : ប្ដឹងទាមទារអោយចុងចម្លើយរុះរើសម្ភារៈចេញពីដី និង ផ្ទះរបស់ខ្លួន

បានឃើញបណ្ដឹងសាទុក្ខលើកទី២លេខ ៤៣៤ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៩៧ របស់ឈ្មោះ វ័ត្ន សុវណ្ណរិទ្ធិ ប្ដឹងមិនសុខចិត្ត និង សាលដីការបស់សាលាឧទ្ធរណ៍ទាំងមូល ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៤០ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ ១៩៩៨ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៩៣ របស់ឈ្មោះ វ័ត្ន សុវណ្ណរិទ្ធ ប្ដឹងទាមទារអោយឈ្មោះ អ៊ុំ បូ រើសំភារៈចេញពីដី និង ផ្ទះរបស់ខ្លួនដោយហេតុថា ដីនេះខ្លួនរស់នៅតាំងពីឆ្នាំ១៩៧៩មក ដែលរដ្ឋអំណាចមូលដ្ឋានប្រគល់អោយខ្លួនធ្វើជាសេដ្ឋកិច្ចគ្រួសារ ។ នៅឆ្នាំ១៩៨១ ខ្លួនបានមកធ្វើការនៅភ្នំពេញ ប្រគល់ដីនេះអោយប្អូនឈ្មោះ វ័ត្ន សម្បត្តិ នៅថែរក្សា ។ នៅឆ្នាំ១៩៨៦ ប្អូនខ្លួនបានមកព្យាបាលជម្ងឺនៅភ្នំពេញ ។ លុះដល់ពេលត្រឡប់មកវិញស្រាប់តែឈ្មោះ អ៊ុំ បូ មករស់នៅលើដី និង ផ្ទះនេះរហូតសព្វថ្ងៃ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ១៤ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៩៤ របស់តុលាការខេត្តកណ្ដាល ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៩៣ របស់ដើមចោទ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-អោយឈ្មោះ អ៊ុំ បូ រុះរើសំភារៈចេញពីផ្ទះ និង ដីរបស់ឈ្មោះវ័ត្ន សុវណ្ណរិទ្ធិ ក្នុងរយៈពេល ៦០ថ្ងៃចាប់ពីថ្ងៃប្រកាសសាលក្រម ។

៣-បង្គាប់អោយឈ្មោះអ៊ុំ បូ បង់ប្រាក់ប្រដាប់ក្ដី គឺ ពន្ធហ្នឹង និងពន្ធចុះបញ្ជីក្ដី ១.៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០រៀល បូករួម ៧.០០០រៀល ដែលបានកាត់យកពីប្រាក់ ៧.០០០រៀល ដែលដើមចោទបានបង់ទុករួចជាស្រេច ។ បើផុតកំណត់ឧទ្ធរណ៍ អោយឈ្មោះ អ៊ុំ បូ ប្រគល់ប្រាក់ ៧.០០០រៀលអោយទៅដើមចោទវិញ និង អោយបង់ពន្ធសមាមាត្រដោយបានពីមាស ២០តម្លឹងស្មើប្រាក់ ២០លានរៀលគុណ១ចែក១០០ ស្មើនិង ២០០.០០០រៀល ក្នុងប្រាក់នេះត្រូវបង់ចូលថវិការដ្ឋ១៦ម៉ឺនរៀល និងរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ៤ម៉ឺនរៀល ។ កំណត់ប្ដឹងឧទ្ធរណ៍រយៈពេល២ខែ ។

៤-សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខគូក្ដី ។ ភាគីណាមិនសុខចិត្តពី

សាលក្រមនេះ មានសិទ្ធិប្តឹងឧទ្ធរណ៍រយៈពេល ២ខែ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ២០៥ ចុះថ្ងៃទី១២ ខែមិនា ឆ្នាំ១៩៩៤ របស់ឈ្មោះ អ៊ុំ បូ ប្តឹងមិនសុខចិត្ត និង សាលក្រមទាំងមូល ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៤៤ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ១៩៩៥ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១២ ខែមិនា ឆ្នាំ១៩៩៤ របស់ឈ្មោះ អ៊ុំ បូ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹង គតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ១៤ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៩៤ របស់តុលាការខេត្តកណ្តាល ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីដែលឈ្មោះអ៊ុំ បូ បានបង់រួចហើយចំនួន១៣.០០០រៀល គឺពន្ធចុះបញ្ជីក្តី និង ពន្ធហ្វីង២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីហឹបប្រាក់៤៥០រៀល ចំណាយក្នុងកិច្ចប្រគល់ដីកាកោះ ១០.០០០រៀល ។

សាលដីកានេះ ប្រកាសជាសាធារណៈ ចំពោះមុខគូក្តី សំរេចបើកផ្លូវសាទុក្ខពីរខែ គិតចាប់ពីថ្ងៃនេះតទៅ ។

បានឃើញបណ្តឹងសាទុក្ខលេខ៤២ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ ១៩៩៥ របស់ឈ្មោះ អ៊ុំ បូ ប្តឹងមិនសុខចិត្ត និងសាលដីការបស់សាលាឧទ្ធរណ៍ទាំងមូល ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១១៦ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៩៥របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលបណ្តឹងសាទុក្ខចុះថ្ងៃទី២២ ខែ០២ ឆ្នាំ១៩៩៥ របស់ឈ្មោះអ៊ុំ បូ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ៤៤ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ១៩៩៥ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ៨៨ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៥របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីដែលឈ្មោះ អ៊ុំ បូ បានបង់នៅតុលាការកំពូល១៩.០០០-រៀលគឺ :

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វីង៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់ ។

-ចំណាយក្នុងការប្រគល់ដីកាកោះ១២.០០០រៀល សរុប១៦.០០០រៀល សល់

៣.០០០រៀល ប្រគល់អោយម្ចាស់ដើមវិញ ហើយតម្រូវអោយលោក វ័ត្ត សុវណ្ណរិទ្ធ សងប្រាក់ ១៦.០០០រៀល ទៅឈ្មោះ អ៊ុំ បូ វិញ ។

៥-សាលដីកានេះប្រកាស នាសវនាការ ជាសាធារណៈនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ ១៩៩៥ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៤៧៦ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ១៩៩៦ របស់សាលាឧទ្ធរណ៍ ដែលសំរេចតាមអំណាចសាលដីការបស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលជំនុំជំរះរឿងក្ដីនេះឡើងវិញ តាមអំណាចសាលដីកាតុលាការកំពូលលេខ ១១៦ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៩៥ ។

២-បដិសេធសាលក្រមលេខ១៤ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ១៩៩៤ របស់តុលាការខេត្តកណ្ដាល ចោលជាអាសារបង់ ។

៣-សំរេចថា ទីតាំងទំនាស់ត្រូវប្រគល់អោយទៅនាងអ៊ុក ម៉ាលីស ធ្វើជាកម្មសិទ្ធិតទៅ ។

៤-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខឈ្មោះអ៊ុក ម៉ាលីស កំបាំងមុខឈ្មោះ វ័ត្ត សុវណ្ណរិទ្ធិ ។ បើកផ្លូវប្ដឹងទាស់ និង សាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងទាស់ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៩៧ របស់ឈ្មោះ វ័ត្ត សុវណ្ណរិទ្ធិ ប្ដឹងមិនសុខចិត្ត និង សាលដីកាលេខ៤៧៦ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ១៩៩៦ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៩៥៤ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលបណ្ដឹងទាស់ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៩៧របស់ វ័ត្ត សុវណ្ណរិទ្ធិ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីកាលេខ ៤៧៦ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ១៩៩៦ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-បង្គាប់អោយ វ័ត្ត សុវណ្ណរិទ្ធិ បង់ប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ គឺពន្ធចុះបញ្ជីក្ដី និង ពន្ធហ្វ្រឹង ២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០រៀល ចំណាយលើកិច្ចប្រគល់ដីកាកោះ ៥.០០០រៀល និងអាជ្ញាធរតុលាការ ៥.០០០រៀល សរុប ១៣.០០០រៀល ដែលបានបង់ម្ដងរួចមកហើយ ។ កាលបើសាលដីកានេះចូលជាស្ថាពរហើយ បង្គាប់អោយឈ្មោះវ័ត្ត សុ-វណ្ណរិទ្ធិ បង់ពន្ធសមាមាត្រមួយភាគរយលើតំលៃដីទំនាស់ ។

៤-សាលដីកានេះប្រកាសជាសាធារណៈ ចំពោះមុខអ៊ុក ម៉ាលីស កំបាំងមុខ វ័ត្ត-សុវណ្ណរិទ្ធិ ជាលើកទី២ ចាត់ទុកជាចំពោះមុខ បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៤៣៤ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៩៧ របស់ឈ្មោះ វ័ត្ត-សុវណ្ណរិទ្ធិ ប្តឹងមិនសុខចិត្ត និងសាលដីការបស់សាលាឧទ្ធរណ៍ទាំងមូល ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញ សាលដីការបៀបលេខ១៨៤ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០២ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១- ចាត់របៀបអោយចៅក្រមប្រឹក្សាតុលាការកំពូល អោយចុះពិនិត្យដល់ទីកន្លែង និង ស៊ើបអង្កេតបន្ថែម ។

២-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី១២ ខែសីហា ឆ្នាំ ២០០២ ។

បានឃើញសារណាការពារចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៨ របស់ឈ្មោះ វ័ត្ត សុវណ្ណរិទ្ធិ ជាម្ចាស់បណ្តឹងសាទុក្ខ ។

បានឃើញសារណាតបចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៨ របស់ឈ្មោះ អ៊ុក ម៉ាលីស ជាចុងបណ្តឹងសាទុក្ខ ។

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-តំណាងមហាអយ្យការ បានធ្វើសេចក្តីសន្និដ្ឋានថា : រឿងនេះជារឿងវិវាទទាមទារផ្ទះ និង ដី ហេតុនេះសូមក្រុមប្រឹក្សាជំនុំជំរះ សំរេចតាមច្បាប់ ។

- បានស្តាប់ចម្លើយ របស់ឈ្មោះ វ័ត្ត សុវណ្ណរិទ្ធិ "ជាម្ចាស់បណ្តឹងសាទុក្ខ" នៅពេលសវនាការថា : នៅឆ្នាំ១៩៧៩ខ្លួនបានសុំផ្ទះ និងដីពីរដ្ឋអំណាច ពេលនោះប្អូនខ្លួនឈ្មោះវ័ត្ត សម្បត្តិ កាន់កាប់ថែរក្សាផ្ទះនោះ ក្រោយមកលោក អ៊ុំ បូរ បានមកសុំប្អូនខ្លួននៅជាមួយ ក្រោយមកទៀត ប្អូនខ្លួនបានធ្លាក់លើដើមស្វាយ ក៏យកមកព្យាបាលនៅភ្នំពេញមួយរយៈ។ លុះដល់ពេលប្អូនខ្លួនត្រឡប់ទៅវិញ ខ្លួននិងប្អូនខ្លួនត្រូវក្រុមគ្រួសារ អ៊ុំ បូរ គំរាមកំហែងមិនឱ្យទៅក្បែរ ។

- បានស្តាប់ចម្លើយរបស់ឈ្មោះ អ៊ុក ម៉ាលីស "ជាចុងបណ្តឹងសាទុក្ខ" នៅពេលសវនាការថា : ខ្លួនមករស់នៅលើផ្ទះទំនាស់នេះ គឺភូមិ-ឃុំ ប្រគល់មកឱ្យខ្លួន វ័ត្ត សុវណ្ណរិទ្ធិ រស់នៅជាមួយប្អូនឈ្មោះ វ័ត្ត សម្បត្តិ គឺគ្មានទេ គឺគេនិយាយបំពាន ទាំងអស់ ។

- បានស្តាប់សេចក្តីសន្និដ្ឋាន របស់លោក ស៊ុម ស៊ីថាន បានធ្វើសេចក្តីសន្និដ្ឋានថា :ខ្លួនសូមឯកភាពសាលក្រមលេខ១៤ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៩៤ របស់តុលាការខេត្តកណ្តាល និងឯកភាពតាម សាលដីការដ្ឋប្បវេណីលេខ៨៤ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ១៩៩៥ របស់សាលាឧទ្ធរណ៍។

- អំពីការកាន់កាប់នឹងការរស់នៅ កូនក្តីខ្លួនឈ្មោះ វ័ត្ត សម្បត្តិ បានបេះផលដំណាំលើដី

ទំនាស់នោះ ជារៀងរហូត គឺស្របតាមមាត្រា១ ,២ ,៦២ ,៦៣ ,៦៤ និង៧៤ ហើយសូមក្រុមប្រឹក្សាជំនុំជំរះពិចារណា សូមឱ្យតុលាការកំពូលមេត្តាតំកល់សាលក្រមលេខ១៤ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៩៤ របស់តុលាការខេត្តកណ្តាល និង សុំតំកល់សាលដីការដ្ឋប្បវេណីលេខ៤៤ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ១៩៩៥ របស់សាលាឧទ្ធរណ៍ទាំងមូល ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីដើមចោទ ។

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**. តុលាការកំពូល**

- យល់ឃើញថា បណ្តឹងសាទុក្ខលើកទី២ លេខ៨៣៤ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៩៧ របស់លោក រ័ត្ន សុវណ្ណរិទ្ធិ ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះដល់អង្គសេចក្តី បានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និង តាមមាត្រា២២៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌដែលមានអនុភាពអនុវត្តក្នុងរឿងរដ្ឋប្បវេណីផងដែរ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចប្រគល់ ដីទំនាស់ទាំងមូលអោយទៅចុងចម្លើយដោយអាងហេតុថា ចុងចម្លើយបានរស់នៅជាអចិន្ត្រៃយ៍ ដែលរដ្ឋអំណាចមូលដ្ឋានបានចែកឱ្យ និង ទទួលស្គាល់នោះជាការពុំត្រឹមត្រូវទេ ពីព្រោះថា :

•នៅតុលាការខេត្តកណ្តាល និង នៅសាលាឧទ្ធរណ៍ ចុងចម្លើយក៏ដូចជាសាក្សីនិងរដ្ឋអំណាចមូលដ្ឋានដែរ សុទ្ធតែឆ្លើយថា ពេលដែលចុងចម្លើយឡើងទៅនៅលើផ្ទះនេះគឺសុំដើមចោទរស់នៅហើយដើមចោទបានរស់នៅមុនរួចទៅហើយ ចំពោះដំណាំក៏ដើមចោទអាស្រ័យផលលើដំណាំចាស់ និង បានដាំថ្មីផងដែរ ។

•ផ្ទះទំនាស់នេះគឺដើមចោទជាអ្នកចេញសោហ៊ុយជួសជុលដំណាំក៏ដើមចោទអាស្រ័យផល ហើយស្តូបចេតីយ៍ក៏ជាទីតំកល់សពឱពុកជីដូន ជីតាដើមចោទដែរ ដែលដើមចោទក៏បានទទួលស្គាល់ថា កន្លងមកខ្លួនមិនហ៊ានប៉ះពាល់ស្តូបចេតីយ៍នេះទេ ពីព្រោះផ្អែកលើអបិយ៍ជំនឿ ។

ដូច្នេះ ចុងចម្លើយមិនអាចមានសិទ្ធិលើទីតាំងដី ដែលមានផ្ទះនិងមានស្តូបចេតិយ៍បានទេ ។

- យល់ឃើញថា ដើម្បីងាយស្រួលក្នុងការសំរេចសេចក្តី តុលាការកំពូលគប្បីកំណត់ជាចំណុច A, B, C, D ,$C^1$, $D^1$,E និង F លើគំនូសប្លង់ដីទំនាស់ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០២ របស់ចៅក្រមតុលាការកំពូល ។

-យល់ឃើញថា ការដែលចុងចម្លើយទាមទារយកដី និង ផ្ទះទំនាស់នេះ ដោយអាងលើរដ្ឋអំណាចមូលដ្ឋានប្រគល់អោយនៅឆ្នាំ១៩៨៥នោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះនៅឆ្នាំ១៩៨៥ ឈ្មោះ រ័ត្ន សម្បត្តិ ដែលជាប្អូនដើមចោទមានគ្រោះថ្នាក់បាក់ចង្កេះ និងបាក់ជើងត្រូវព្យាបាលយូរនៅភ្នំពេញ។ ដូច្នេះការដកយកដីពីពលរដ្ឋមួយដែលកំពុងកាន់កាប់ យកទៅអោយពលរដ្ឋមួយទៀត ដែលមិនមែនជាប្រយោជន៍សាធារណៈនោះជាការពុំត្រឹមត្រូវទេ ។

- យល់ឃើញថា ការដែលដើមចោទចេញ មកព្យាបាលនៅភ្នំពេញនៅឆ្នាំ១៩៨៥ ហើយបានប្តឹងទាមទារយកដី និង ផ្ទះទំនាស់នេះរហូតមកនោះក្រោយការកំរាមកំហែងពីចុងចម្លើយ ពុំអាចចាត់ទុកជាការបោះបង់ចោលនូវដី និង ផ្ទះទំនាស់នេះទេ ។

- យល់ឃើញថា នៅពេលដែលកំពុងប្តឹងគ្នានៅតុលាការ ចុងចម្លើយបានបំពានវាយកំទេចផ្ទះទំនាស់ចោលយកដែក និងកំទេចថ្នលក់នៅឆ្នាំ១៩៩៩ ទោះបីតុលាការបានហាមឃាត់រួចហើយក្តី។ ប៉ុន្តែភស្តុតាងនៃគ្រឹះផ្ទះនៅមាននៅឡើយ ហើយស្តូបចេតិយ៍ ក៏នៅមានជាភស្តុតាងដែរ ។

- យល់ឃើញថា ដោយចុងចម្លើយដែលបានរស់នៅលើដីទំនាស់នេះជាយូរដែរ ក៏មានសិទ្ធិដូចដើមចោទដែរនោះ តុលាការកំពូលគប្បីបែងចែកដីទំនាស់នេះជាពីរចំណែក តាមសមធម៌ និងតាមសភាពជាក់ស្តែងនៃទីតាំងដីទំនាស់ ។ បច្ចុប្បន្នស្តូបចេតិយ៍ ,ខឿនផ្ទះទំនាស់ ,ដំណាំចាស់ដែលដើមចោទបានកាន់កាប់ស្ថិតនៅផ្នែកខាងត្បូង ដូច្នេះគួរបែងចែកផ្នែកខាងត្បូងអោយដើមចោទ តាមចំណុច CDEFC ហើយប្រគល់ផ្នែកខាងជើង ឱ្យចុងចម្លើយតាមចំណុច ABCDA ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៥៥៤ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៩៧របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះ មានការខុសឆ្គង ទាំងទំរង់ ទាំងគតិច្បាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីទំនោះមុខ ថ្មី**

១- ទទួលបណ្តឹងសាទុក្ខលើកទី២លេខ ៤៣៤ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៩៧ របស់លោក រ័ត្ន សុវណ្ណរិទ្ធិ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ខ្លះ ។

២- ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ៥៥៤ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ ទាំងមូល ។

៣- សំរេចបែងចែកទីតាំងដីទំនាស់ជា២ចំណែក :

ក-ផ្នែកខាងត្បូងទំហំ CDEFC ដែលមានជ្រុង[CD]=[EF]=៤០,២០ម ហើយជ្រុង[DE]=៦៦,៥០ម និងជ្រុង[CF]=៦៩,៥០ម អោយទៅដើមចោទគ្រប់គ្រងកាន់កាប់តទៅ ។

ខ-ប្រគល់ផ្នែកខាងជើងទំហំ ABCDA ដែលមានជ្រុង[AB]=[CD]=៤០,២០ម

ហើយជ្រុង[AD]=[BC]=៦៧,៥០ម អោយទៅចុងចម្លើយគ្រប់គ្រងកាន់កាប់តទៅ ។

គ-ដំណាំទាំងឡាយដែលស្ថិតនៅលើចំណែកដីដែលគូភាគីបានទទួល គូភាគីមានសិទ្ធិអាស្រ័យផលតាមចំណែករៀងៗខ្លួន ។

៤- រ៉ាប់អូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០រៀល ដែលអ្នកស្រី អ៊ុក ម៉ាលីស បានបង់គឺ :

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀលសំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយលើការប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប ១៩.០០០រៀល ។

បង្គាប់ឱ្យចុងចម្លើយ បង់ពន្ធសមាមាត្រ១% លើតម្លៃដីដែលត្រូវបានទៅដើមចោទ និង បង្គាប់អោយដើមចោទ បង់ពន្ធសមាមាត្រ១% លើតម្លៃដីដែលត្រូវបានទៅចុងចម្លើយ ។

៥- សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៣ ខែមិនា ឆ្នាំ២០០៣។